# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 09-Aug-2016, 14:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សំណើសាជាថ្មីរបស់មេធាវីការពារក្ដីលោក ខៀវ សំផន
## សុំស្ដាប់សក្ខីកម្មសាក្សី 2-TCE- 87 និង 2-TCE-99

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

**ជំនួយការ៖**

លោកស្រី សេង សុជាតា

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ូរ ឧត្តរា

ចៅក្រម Claudia FENZ

ចៅក្រម យ៉ា សុខន

កញ្ញា Marie CAPOTORTO
កញ្ញា Soumeya MEDJEBEUR
លោក Clément BOSSIS
កញ្ញា Cécile ROUBEIX
កញ្ញា អ៊ុច ស្រីផាត
លោក តាន់ ឆាយរ័ត្ន

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្តីលោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") បានដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញមួយចំនួនតូច ដែលខ្លួនស្នើសុំស្តាប់សក្ខីកម្ម ក្នុងសំណុំរឿង ០០២/០២[1] ក្នុងនោះមាន 2-TCE-94 ក្នុងឋានៈជាអ្នកជំនាញ ព្រមទាំង 2-TCE-87 និង 2-TCE-99 ក្នុងឋានៈជាសាក្សី "ដឹងឮ"[2]។

២. នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានជូនដំណឹងដល់ភាគីអំពីសេចក្តីសម្រេចស្តាប់សក្ខីកម្ម 2-TCE-94 ក្នុងឋានៈជាអ្នកជំនាញ[3]។ អង្គជំនុំជម្រះបានចេញសំអាងហេតុនៃសេចក្តីសម្រេចរបស់ខ្លួន នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៦[4]។

៣. នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ ក្រោយពីអ្នកជំនាញ 2-TCE-94 បដិសេធមិនព្រមចូលមកបង្ហាញខ្លួន អង្គជំនុំជម្រះបានសម្រេចដកឈ្មោះគាត់ចេញពីបញ្ជីឈ្មោះបុគ្គល ដែលត្រូវបានជ្រើសរើសឲ្យមកផ្តល់សក្ខីកម្ម[5]។

៤. នៅថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានជម្រាបអំពីចេតនាក្នុងការស្នើសុំអ្នកមក "ជំនួស" 2-TCE-94 នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ ដែលគ្រោងនឹងរៀបចំឡើង នារសៀលថ្ងៃ

[1] សាក្សី និងអ្នកជំនាញ ស្នើឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **E305/5**, ឧបសម្ព័ន្ធ **E305/5.1** (បញ្ជីឈ្មោះ) និងឧបសម្ព័ន្ធ **E305/5.2** (សេចក្តីសង្ខេបនៃសក្ខីកម្មរបស់សាក្សី និងអ្នកជំនាញ ដែលបានស្នើសុំ)។

[2] គឺមានន័យថា បុគ្គលមានឋានៈចម្រុះ ដែលអាចត្រូវបានស្តាប់សក្ខីកម្ម ក្នុងឋានៈជាសាក្សី ឬជាអ្នកជំនាញ ឬក្នុងឋានៈជាអ្នកជំនាញផង និងជាសាក្សីផង ក្នុងពេលតែមួយ។

[3] អ៊ីមែលរបស់លោក ROBERTS ផ្ញើនៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ វេលាម៉ោង ១០ និង ៤៤ នាទី មានចំណងជើងថា៖ "ការបោសសម្អាតផ្ទៃក្នុង៖ បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ" (ភ្ជាប់ជាឧបសម្ព័ន្ធ)។

[4] សេចក្តីសម្រេចលើការតែងតាំងអ្នកជំនាញ ដែលមានរហស្សនាម 2-TCE-94 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ **E408**។

[5] អ៊ីមែលរបស់លោក CRIPPA ផ្ញើនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ វេលាម៉ោង ០៨ និង ៥២ នាទី មានចំណងជើងថា៖ "កម្មវត្ថុ៖ កាលវិភាគសវនាការ" (ភ្ជាប់ជាឧបសម្ព័ន្ធ)។

ទី ០៤ ខែ សីហា ឆ្នាំ ២០១៦[6]។

៥. នៅព្រឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានបដិសេធស្តាប់សំណើនេះ ក្នុងកិច្ចប្រជុំរៀបចំសវនាការ ដោយបញ្ជាក់ថា អង្គជំនុំជម្រះកំពុងរៀបចំបញ្ចប់នូវបញ្ជីឈ្មោះបុគ្គលចុងក្រោយដែលនឹងត្រូវកោះហៅឱ្យមកផ្តល់សក្ខីកម្ម[7]។

៦. ដូច្នេះ តាមរយៈសំណើនេះ មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះស្តាប់សក្ខីកម្មសាក្សី 2-TCE-87 និង 2-TCE-99 "ជំនួស" ឱ្យអ្នកជំនាញ 2-TCE-94 ក្នុងករណីអង្គជំនុំជម្រះមិនបានគ្រោងស្តាប់សក្ខីកម្មបុគ្គលទាំងពីររូបនេះទេ ក្នុងអំឡុងសវនាការចុងក្រោយលើសំណុំរឿង ០០២/០២។

៧. ពិតណាស់ វាជាការចាំបាច់ត្រូវ "ជំនួស" 2-TCE-94 ដោយសារតែគាត់ជាអ្នកជំនាញតែមួយគត់ដែលស្នើឡើងដោយមេធាវីការពារក្តី និងដែលអង្គជំនុំជម្រះបានសម្រេចកោះហៅ៖ អ្នកជំនាញទាំងបួនរូប ដែលបានមកផ្តល់សក្ខីកម្ម មកទល់នឹងពេលនេះ សុទ្ធតែត្រូវបានស្នើឡើងដោយសហព្រះរាជអាជ្ញា[8]។ ដូច្នេះ អង្គជំនុំជម្រះត្រូវស្តាប់សក្ខីកម្មបុគ្គល ដែលស្នើឡើងដោយមេធាវីការពារក្តី ក្នុងគោលដៅទទួលបានប្រទីបបំភ្លឺមួយទៀត ដើម្បីប្រយោជន៍យុត្តិធម៌ និងស្វែងរកការពិត។

៨. សាក្សី "ដឹងឮ" 2-TCE-87 និង 2-TCE-99 ដែលស្នើឡើងដោយមេធាវីការពារក្តី មានចំណុចរួមគ្នាជាច្រើនជាមួយអ្នកជំនាញ 2-TCE-94 ដូចបានរៀបរាប់នៅក្នុងសេចក្តីសម្រេចលើការតែងតាំងអ្នកជំនាញរូបនេះ[9]។ ជាក់ស្តែង អ្នកទាំងបីសុទ្ធតែធ្លាប់រស់នៅប្រទេសកម្ពុជា មុនឆ្នាំ១៩៧៥ និង

---

[6] អ៊ីមែលរបស់មេធាវីការពារក្តី ផ្ញើនៅថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោង ១១ និង ៣១ នាទី មានចំណងជើងថា៖ "កិច្ចប្រជុំរៀបចំសវនាការ នៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦" (ភ្ជាប់ជាឧបសម្ព័ន្ធ)។

[7] អ៊ីមែលរបស់លោក CRIPPA ផ្ញើនៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោង ០៩ និង ៣៦ នាទី មានចំណងជើងថា៖ "របៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការ នៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦" (ភ្ជាប់ជាឧបសម្ព័ន្ធ)។

[8] អ្នកជំនាញ 2-TCE-97 អ្នកជំនាញ 2-TCE-95 អ្នកជំនាញ 2-TCE-88 និងអ្នកជំនាញ 2-TCE-90។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានសម្រេចស្តាប់នាពេលខាងមុខនេះនូវសក្ខីកម្មអ្នកជំនាញមួយរូប ដែលស្នើឡើងដោយសហព្រះរាជអាជ្ញា និងអ្នកជំនាញមួយរូបដែលស្នើឡើងដោយមេធាវីការពារក្តី ប៉ុន្តែ កម្រិតត្រឹមវគ្គស្តីពីការគ្រប់គ្រងលើការរៀបអាពាហ៍ពិពាហ៍ប៉ុណ្ណោះ។

[9] សេចក្តីសម្រេចលើការតែងតាំងអ្នកជំនាញ ដែលមានរហស្សនាម 2-TCE-94 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ **E408** កថាខណ្ឌ ១៤-១៧។

ក្រោយឆ្នាំ១៩៧៩ ពួកគាត់និយាយភាសាខ្មែរយ៉ាងស្ទាត់ជំនាញ និងមានស្ថានភាពពិសេសជាអ្នកប្រមូលចងក្រងសក្ខីកម្មពីដំបូងដែ។ ពួកគាត់បានធ្វើការស្រាវជ្រាវ និងទទួលបានបទពិសោធន៍យ៉ាងទូលំទូលាយ ដើម្បីជួយដល់អង្គជំនុំជម្រះ។ ដូច្នេះ អ្នកទាំងបីអាចត្រូវបានស្តាប់ចម្លើយ ក្នុងឋានៈជាអ្នកជំនាញ ឬសាក្សីអង្គហេតុ។ លើសពីនេះទៀត ដូចអ្នកជំនាញ 2-TCE-94 ដែរ សាក្សី 2-TCE-87 និង 2-TCE-99 អាចផ្តល់សក្ខីកម្មលើប្រធានបទជាច្រើន ក្នុងសំណុំរឿង ០០២/០២។

៩. ក្រៅពីចំណុចរួមទាំងនេះ សាក្សី 2-TCE-87 និង 2-TCE-99 មានចំណេះដឹងជ្រៅជ្រះ ដែលអាចផ្តល់ជាប្រទីបបំភ្លឺដល់អង្គជំនុំជម្រះ ជាអាទិ៍ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងមនោគមន៍វិជ្ជា សម្រាប់សាក្សី 2-TCE-87 ឬវប្បធម៌ និងសាសនា សម្រាប់សាក្សី 2-TCE-99[10]។

១០. **<u>អាស្រ័យហេតុនេះ</u>** មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះមេត្តា**កោះហៅ**សាក្សី 2-TCE-87 និង 2-TCE-99 ឲ្យមកផ្តល់សក្ខីកម្ម។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>រាជធានីភ្នំពេញ | |

[10] ដើម្បីលាក់អត្តសញ្ញាណបុគ្គលទាំងពីររូបនេះ មេធាវីការពារក្តីមិនរៀបរាប់លម្អិតច្រើនពេកទេ ដោយសារតែអង្គជំនុំជម្រះដឹងច្បាស់រួចទៅហើយ។